MJP មូលនិធិ ម៉ាដក្សចូលីភីត
Maddox Jolie-Pitt Foundation

ACIAR
aciar.gov.au

Australian Government
Australian Centre for
International Agricultural Research

MJP មូលនិធិ ម៉ាដក្សចូលីភីត
Maddox Jolie-Pitt Foundation

# ស្ត្រី និងសួនបន្លែ



មជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ត្រូវបានបង្កើតឡើងនៅ ខែមិថុនា ឆ្នាំ១៩៨២ដោយច្បាប់របស់រដ្ឋសភាអូស្ត្រាលី។ មជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការស្រាវជ្រាវ (ACIAR) ជាផ្នែកមួយនៃកម្មវិធីសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍន៍ អន្តរជាតិនៃប្រទេសអូស្ត្រាលីដែលមានបេសកកម្មធ្វើអោយជោគជ័យនូវប្រពន្ធ័កសកិម្មដែលផ្តល់ផលច្រើន និងមាននិរន្តរភាពសម្រាប់ជាប្រយោជន៍នៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍និងប្រទេសអូស្ត្រាលី។ វាផ្តល់អទិភាពដល់ការស្រាវជ្រាវដែលសហការគ្នារវាងអ្នកស្រាវជ្រាវនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងអ្នកស្រាវជ្រាវប្រទេសអូស្ត្រាលីដែលប្រទេសអូស្ត្រាលី ជាប្រទេសដែលមានសមត្ថភាពពិសេស ខាងសិក្សាស្រាវជ្រាវលើវិស័យកសិកម្ម។ វាក៏ជាវិភាគទានរបស់អូស្ត្រាលីលេការគ្រប់គ្រងមជ្ឈមណ្ឌលសំរាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ។ ការប្រើប្រាស់ឯកសារឬឈ្មោះនេះមិនមែនជាការរើសអើងឬជាការនិយមរបស់មជ្ឈមណ្ឌលឡើយ។

**កម្រងឯកលេខនារបស់ ACIAR**

សៀវភៅទាំងនេះ មានបញ្ចូលលទ្ធផលនៃការស្រាវជ្រាវដំបូងដែលឧបត្ថម្ភ ដោយមជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ឬឯកសារដែលទាក់ទងនឹងការស្រាវជ្រាវ និងទិសដៅនៃការអភិវឌ្ឍន៍របស់ ACIAR។ កម្រងសៀវភៅនេះ ត្រូវបានចែកចាយជាលក្ខណៈអន្តរជាតិ ដែលសង្កត់ធ្ងន់ទៅលើប្រទេសកំពុងអភិវឌ្ឍន៍។

**© មជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ ACIAR ២០១២**

សៀវភៅនេះត្រូវបានរក្សាសិទ្ធិ។ ក្រៅពីការប្រើប្រាស់ណាមួយដែលត្រូវបានអនុញ្ញាតដូចមានតែងក្នុងច្បាប់រក្សាសិទ្ធិឆ្នាំ១៩៦៨ (Copyright Act ១៩៦៨) ។ គ្មានផ្នែកណាមួយនឹងអាចត្រូវបានយកទៅផលិតសារឡើងវិញតាមមធ្យោបាយណាមួយ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពី ACIAR ដែលមានអាស័យដ្ឋាន GPO Box 1571, Canberra ACT 2601, Australia, aciar@aciar.gov.au ។

**សហការបោះពុម្ពដោយ ACIAR និងមូលនិធិម៉ាដក្សចូលីភីត (MJP)**

អ៊ែមចេភីមានការប្តេជ្ញាចំពោះសុវត្ថិភាពបរិស្ថានការបង្កើតស្នេរភាពនិងសន្តិភាពនៅក្នុងសហគមន៍ទាំងអស់ ដោយការធ្វើផែនការនិងការអនុវត្តន៍សកម្មភាពទាំងឡាយដែលការពារបំរែបំរួលបរិស្ថានអវិជ្ជមាន។ ដោយការធ្វើការជាមួយប្រជាជននៅតាមជនបទក្រីក្រ និង រដ្ឋាភិបាលក្នុងតំបន់ដើម្បីកាត់បន្ថយអសុវត្ថភាពស្បៀងអាហារនិងបង្កើនលទ្ធភាពទទួលបានសេវាថែរទាំសុខភាពនិងអប់រំជាបឋម អ៊ែមចេភីកំពុងតែអនុវត្តគំរោង ដែលកសាងបាននូវសហគមន៍ដែលស្រស់បំព្រងនិងរឹងមាំ។

ACIAR និង MJP ២០១២។ សៀវភៅសុភី និងសូនបន្លែ។ ACIAR Monograph 152a។ មជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ និងមូលនិធិម៉ាដក្សចូលីភីត Canberra ៤៤ទំព័រ ។

ACIAR Monograph 152a

ISBN 978 1 921738 65 4 (បោះពុម្ព)
ISBN 978 1 921738 66 1 (អ៊ីនធើណឹត)

រចនានិងបោះពុម្ពដោយរោងពុម្ពហ្គ្រែនអាត
Grand Arts Printing House, Phnom Penh
រូបភាពដោយ សឹង្ហ មករា
(Grand Arts Printing House, Phnom Penh)

# សុភី និងសួនបន្លែ

## ២០១២



នៅ ភូមិជនបទនាស្រុកសំឡូតមានផ្ទៃមេឃស្រឡះ អាកាសធាតុល្អ ព្រះអាទិត្យកំពុងតែបញ្ចេញកំដៅធ្វើដំណើរឆ្លងកាត់ដែនដីនៃស្រុកសំឡូត ។ នេះជារដូវវស្សា ហើយក៏ជាពេលដែលដុំពពកទាំងឡាយហោះហើរពាសពេញផ្ទៃមេឃនឹងនាំមកជាមួយនូវទឹកភ្លៀងដែលជាអំណោយទានដ៏ពិសេសពីធម្មជាតិ ។ កំឡុងពេលនេះដែរប្រជាជនកំពុងតែរង់ចាំទឹកភ្លៀងនាដើមរដូវវស្សាដើម្បីដាំដំណាំ និងស្រោចស្រពកសិផលរបស់ពួកគាត់យ៉ាងអន្ទះសាររកទីបំផុតគ្មាន ។ រៀងរាល់ឆ្នាំតែងតែមានភ្លៀងធ្លាក់មកលើភូមិឋានរបស់ប្រជាកសិករនារដូវវស្សាដើមឆ្នាំ ។ ប៉ុន្តែអកុសលឆ្នាំនេះមិនមានភ្លៀងធ្លាក់សោះ ។







ព្រឹកថ្ងៃច័ន្ទនេះ ធីតាកំពុងតែអន្ទះអន្ទែងរង់ចាំសូភីដែលជាមិត្តជិតស្និទបំផុតរបស់នាងក្នុងបរិវេណសាលារៀនដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់សំរាប់ថ្ងៃចុងសប្តាហ៍របស់ពួកគេ។ ជិតដល់ម៉ោងចូលរៀនទៅហើយនៅតែមិនទាន់ឃើញសូភីមកដល់សាលារៀនទៀត។ ធីតាក៏សំរេចចិត្តចូលទៅក្នុងថ្នាក់រៀនមុនសូភីទាំងក្តីព្រួយបារម្ភ។



បន្ទាប់ចេញពីសាលារៀន ធីតាសំរេចចិត្តទៅលេងផ្ទះសូភីដើម្បីសួរសុខទុក្ខនាង និងមូលហេតុដែលនាងមិនបានមកសាលារៀន ។

ធីតាស្រែកហៅ "សូភី!" ហើយនិយាយទៀតថា "ដំណាំរបស់ឯងមើលទៅល្អណាស់!"





"អរគុណហើយធីតា" សូភីនិយាយដោយមោទនភាព "ខ្ញុំគិតថាកម្មវិធីពិសេសអំពីស្រើងចង្រៃ និងស្រើងមានប្រយោជន៏ ដែលយើងបានរៀនកាលពីឆ្នាំមុនពិតជាមានប្រយោជន៏ណាស់" សូភីនិយាយទាំងញញឹម ។

"ទំនងជាអញ្ចឹងមែនហើយ! ។ ហេតុដូចម្ដេចបានជាឯងមិនទៅរៀនថ្ងៃនេះ?" ធីតាសួរសូភី ។





សូភីពន្យល់ធីតាពីមូលហេតុដែលនាងមិនបានទៅរៀន គឺដោយសារតែឪពុករបស់នាងត្រូវចេញពីផ្ទះនៅពេលព្រឹកព្រលឹម ដើម្បីទៅពិភាក្សាជាមួយកសិករទាំងអស់អំពីដំណាំរបស់ពួកគាត់ និងបញ្ហាមិនមានភ្លៀងធ្លាក់មកសោះនៅដើមឆ្នាំនេះ ។

ដោយហេតុថាគ្មានភ្លៀង សូភីត្រូវជួយម្ដាយ និងប្អូនប្រុសរបស់នាង (សារ៉េត) ក្នុងការដងទឹកពីក្នុងស្ទឹងមកស្រោច ត្រកួន ប៉េងប៉ោះ ពោត និងសណ្ដែកកួរ ដែលជាដំណាំប្រចាំគ្រួសារនាង ។

"សូភីឯងពិតជាប្រឹងប្រែងស្រោចស្រពដំណាំទាំងអស់បានល្អណាស់"

ធីតានិយាយ ។

"ឥឡូវយើងចូលទៅក្នុងផ្ទះ ខ្ញុំនឹងប្រាប់ឯងពីមេរៀនដែលឯងមិនបានរៀននៅថ្ងៃនេះ ។"



សូភីដើរបណ្ដើរ រៀបរាប់ប្រាប់ធីតាអំពីស្ថានភាពស្គមស្លេកស្លាំង អស់កំលាំងរបស់ម្ដាយនាង និងប្អូនប្រុស ( សារ៉េត ) ដែលកន្លងមក ពួកគេត្រូវដើរទៅដងទឹកក្នុងស្ទឹងស្រោចដំណាំ ។ នាងមានការព្រួយបារម្ភអំពីប្អូនប្រុសតូចរបស់នាងឈ្មោះ ទូច ដែលមើលទៅហាក់ដូចជាទន់ខ្សោយ អស់កំលាំង និងមិនលេងច្រើនដូចពេលមុន ។





នៅខាងក្នុងផ្ទះ សូភីអង្គុយផ្អៀងខ្លួនមករកធីតាហើយនិយាយ

"ការចុះដងទឹកមកស្រោចស្រពដំណាំថ្ងៃនេះបានធ្វើអោយខ្ញុំដឹងថាតើយើងត្រូវការទឹកភ្លៀងខ្លាំងប៉ុណ្ណា? ។ ពួកយើងមិនអាចបន្តដងទឹកពីស្ទឹងរហូតនោះទេ ។ ម្យ៉ាងវិញទៀតស្ទឹងក៏ជិតរីងស្ងួតអស់ហើយដែរ ។ ប៉ុន្តែបើគ្មានទឹកគ្រប់គ្រាន់គ្រួសារនឹងមិនមានផលដំណាំសំរាប់លក់និងមិនមានលុយកាក់គ្រប់គ្រាន់សំរាប់ទិញអាហារនោះទេ ។"





"ខ្ញុំដឹងហើយ" ធីតានិយាយដោយទំលាក់មុខចុះហើយបន្តថា

"ឯងអាចញ៉ាំអាហារថ្ងៃត្រង់នៅសាលារៀនជាមួយខ្ញុំបាននៅថ្ងៃស្អែក" ។

"អរគុណហើយធីតា ។ ជួបគ្នាថ្ងៃស្អែក ។"





រសៀលថ្ងៃបន្ទាប់ពេលសូភីចេញពីសាលារៀននាងឃើញ ម្តាយរបស់នាង និងទូចគេងយ៉ាងល្វិតល្វៃនៅលើគ្រែ ។ ទូចមានអាយុ ៩ខែ ទៅហើយប៉ុន្តែវាមើលទៅស្គមតូចហាក់ដូចជាកូនង៉ាតូចមួយ និងមិនមានកំលាំងកំហែងសោះ ។ នាងដឹងថានាងត្រូវធ្វើអ្វីមួយ ។ នាងត្រូវតែយកពួកគេទាំងពីរនាក់ទៅកាន់មណ្ឌលសុខភាព ។ តែមណ្ឌលសុខភាពស្ថិតនៅឆ្ងាយពីផ្ទះរបស់នាងណាស់ ហេតុដូច្នេះនាងពរទូចរហូតហើយពេលខ្លះនាងឈប់សំរាកនៅតាមផ្លូវដើម្បីអោយម្តាយរបស់នាងបានសំរាកធូរស្បើយពីភាពនឿយហត់ ។

ពេលទៅដល់មណ្ឌលសុខភាព ពួកគេបានជួបគ្រូពេទ្យម្នាក់ពោរពេញទៅស្នាមញញឹមទទួលរួសរាយរាក់ទាក់ដាក់សូភី ដែលនាងមិនធ្លាប់ជួបនិងឃើញពីមុនមក ។ គ្រូពេទ្យក្រឡេកមើលសុវណ្ណីនិងទូចដោយសេចក្តីស្រលាញ់ហើយពន្យល់សូភីថា "ម្តាយរបស់នាង និងប្អូនប្រុសតូចរបស់នាងមានភាពហត់នឿយ និងខ្សោយកំលាំង ដោយសារតែពួកគេមិនបានទទួលអាហារមានជីវជាតិគ្រប់គ្រាន់ ដូចជា ជាតិប្រូតេអ៊ីន វីតាមីន និង ជាតិដែកជាដើម ។"

គាត់និយាយបន្តទៀតថា "វិធីជួយពួកគេបានលឿនបំផុតដើម្បីអោយមានសុខភាពល្អប្រសើរជាងមុន គឺត្រូវអោយពួកគេញ៉ាំអាហារមានជីវជាតិដែក អោយបានច្រើនដូចជាអាហារ ដែលមាននៅក្នុងផ្ទាំងរូបភាពនេះ ។" គ្រូពេទ្យនិយាយក្នុងខណៈដែលគាត់ហុចផ្ទាំងរូបភាពធំមួយអោយសូភីយកទៅផ្ទះ ។

ប្អូនដឹងទេប្អូនអាចរៀបចំសួនបន្លែមួយដោយខ្លួនឯងហើយដាំបន្លែទាំងអស់នេះបាន ។"

*ហ៊ឺ... ខ្ញុំរាល់ថ្ងៃតែងតែញ៉ាំអាហារដូចម្តាយខ្ញុំ*
*និងទូចដែរចុះហេតុអ្វីខ្ញុំមិនមានជំងឺនេះ?* សូភីសួរខ្លួនឯង ។





នៅតាមផ្លូវធ្វើដំណើរទៅផ្ទះ សូភីគិតអំពីសំដីរបស់គ្រូពេទ្យ ដែលបាននិយាយ ហើយរិះរកវិធីដើម្បីបង្កើតសួនបន្លែយ៉ាងពិសេសមួយ សំរាប់គ្រួសារនាង។ នាងត្រូវការដីដែលមានជីជាតិល្អ ដីធូរ ហើយមានសំណើម និងគ្រាប់ពូជមួយចំនួន។

*តើខ្ញុំត្រូវចាប់ផ្ដើមធ្វើយ៉ាងដូចម្ដេច?*

រំពេចនោះ នាងឈប់ ហើយស្រែកឡើងខ្លាំងៗថា "ខ្ញុំដឹងហើយៗ" ។



សូភីនឹកឃើញដល់អ្នកជិតខាងដ៏ល្អរួសរាយរាក់ទាក់របស់នាងម្នាក់ គឺសេរី ។
មុននឹងទូចកើតមក នាងធ្លាប់ជួយធ្វើការផ្សេងៗ អោយសេរីពេលទំនេរពី
ម៉ោងសិក្សានៅសាលារៀន ។ សេរីជានិច្ចកាលមានទឹកចិត្តល្អអោយបន្លែ
និងពងមាន់មួយចំនួនទៅសូភីញ៉ាំនៅពេលដែលនាងជួយធ្វើការអោយសេរី ។
សេរីចិញ្ចឹមមាន់បានល្អជាងគេបំផុតនៅក្នុងភូមិ ហើយគ្រប់គ្នាតែងតែគិតថា
នាងមានអាថិកំបាំងពិសេស ដែលបានធ្វើអោយមាន់របស់នាងធំធាត់ល្អ
និងមានរោមស្អាតថែមទៀត ។



ហេតុដូច្នេះហើយទើបខ្ញុំមិនមានជំងឺឬអារម្មណ៍ហេវហត់សោះ
ពីព្រោះខ្ញុំញុំាំនូវអាហារចំរុះជាច្រើនមុខ ។ វាមិនគ្រាន់តែពងមាន់ប៉ុណ្ណោះទេ
វាជាម្ហូបដែលមានលាយបន្លែជាច្រើនមុខដ៏ឆ្ងាញ់របស់សេរីផងដែរ ។
សូភីដឹងខ្លួនហើយរំភើបរីករាយ ។





ព្រឹកថ្ងៃបន្ទាប់ សូភីក្រោកឡើងពីព្រលឹមហើយទៅលេងផ្ទះសេរី ។ នៅពេលនាងទៅដល់ សេរីសប្បាយចិត្តខ្លាំងណាស់ដែលបានជួបសូភី ។ "សួស្តីសូភី! (សេរីស្រែកខ្លាំងៗខណៈដែលនាងរត់ទៅអោបសូភី) ។ ខ្ញុំមិនបានជួបឯងជាយូរថ្ងៃមកហើយ ។"

"អោយខ្ញុំសូមទោសបងសេរី ។ ម្តាយខ្ញុំគាត់មិនសូវស្រួលខ្លួនទេ ចាប់តាំងពីគាត់មានទូចមក ។" សូភីនិយាយ

"ព្រះអើយ! តើយើងអាចជួយគាត់បានដូចម្តេចខ្លះ?" សេរីសួរដោយក្តីបារម្ភ

"យើងអាចជួយគាត់បានបងសេរី ។ តើបងអាចជួយបង្ហាញវិធីដាំបន្លែទាំងនេះដល់ខ្ញុំបានទេ?"សូភីនិយាយ ដោយលើកផ្ទាំងរូបភាពដែលគ្រូពេទ្យអោយនាងមកបង្ហាញផង ។

"ចាស៎បាន" ។ សេរីពន្យល់ថាអាហារដែលសំបូរទៅដោយជាតិដែកមានសារៈសំខាន់ខ្លាំងណាស់សំរាប់យើងទាំងអស់គ្នានៅស្រុកសំឡូត ។ ពួកវាជួយយើង ឱ្យមានកំលាំងមាំមួន និងមានសុខភាពល្អ ។ តោះ! ចូលក្នុងសួនបន្លែ ចាំខ្ញុំបង្ហាញឯង ។"



នៅក្នុងសួនបន្លែសូភីឃើញដីដ៏មានជីល្អ ខ្មៅហើយសើម បន្លែពណ៌បៃតងស្រស់ៗជាច្រើនមុខដុះនៅក្នុងទីធ្លាធំមួយ ។

សេរីចាប់ផ្ដើមពន្យល់សូភីអំពីឈ្មោះ និងប្រភេទបន្លែនីមួយៗ "នេះជាត្រកួន នេះជាប៉េងប៉ោះ នេះជាពោត ហើយមួយនេះសណ្ដែកកួរ ហើយខាងណោះគឺល្ពៅ ។ សេរីនិយាយថា "ខ្ញុំអាចប្រាប់ពីរបៀបដាំបន្លែទាំងនេះដល់ឯង ហើយអាចអោយគ្រាប់ពូជខ្លះៗទៅឯងបើសិនជាឯងត្រូវការ" ។

សូភីនិយាយ "អរគុណណាស់ បងសេរី ប៉ុន្តែនៅផ្ទះខ្ញុំ ដីមិនល្អដូចដីនៅផ្ទះបងទេ ។ វាស្ងួត ហើយសំបូរថ្មទៀតផង ។ ខ្ញុំគិតថាដំណាំមិនអាចដុះបានល្អនោះទេ" ។ សូភីនិយាយដោយឱនមុខចុះ ។



សេរីនិយាយថា "ឯងកុំបារម្ភធ្វើអ្វី ខ្ញុំនឹងទៅផ្ទះឯងដើម្បីជួយបង្ហាញអំពីវិធីរៀបចំដី និងវិធីការពារដីដើម្បីកុំអោយវាត្រូវការទឹកច្រើនពេក។ ដោយសារតែគ្មានទឹកភ្លៀងឯងចាំបាច់ត្រូវរក្សានូវសំណើមទាំងអស់នៅក្នុងដី។

ឯងឃើញដីខ្មៅផុសៗនេះទេ?"

សូភីងក់ក្បាលតិចៗ។

"គេហៅវាថា កំប៉ុស យើងត្រូវការវាដើម្បីធ្វើឱ្យដីរបស់យើងមានជីវជាតិសំរាប់ដាំដំណាំ។ ឯងអាចធ្វើជីកំប៉ុសនេះពីដើមរុក្ខជាតិនៅជុំវិញផ្ទះដោយខ្លួនឯងបាន។ យើងអាចប្រើរយៈពេលយូរបន្តិចដើម្បីធ្វើជីនេះ។ យប់នេះ ខ្ញុំនឹងឱ្យបងវុទ្ធីប្ដីរបស់ខ្ញុំជួយដឹកជីកំប៉ុសមួយរទេះ ទៅដាក់នៅផ្ទះរបស់ឯង។ យើងអាចចាប់ផ្ដើមធ្វើសួននៅថ្ងៃស្អែកបាន។"

"អរគុណច្រើនបងសេរី ។  បងជាអ្នកជិតខាងដ៏ល្អជាងគេនៅក្នុងភូមិ"

"មិនអីទេសូភី ។ សូភីយកពងមាន់ និងបន្លែមួយកន្ត្រកនេះទៅផ្ទះចុះ ។ ឯងអាចស្ងោពងមាន់ និងធ្វើម្ហូបពីបន្លែទាំងនេះ ។ ប៉ុន្តែកុំរម្ងាស់បន្លែយូរពេកជាពិសេសបន្លែបៃតង គ្រាន់តែអោយវារញោមទន់ត្រូវលើកវាចុះពីភ្លើងបានហើយ ។ ឯងឆាត្រឡប់ជាមួយខ្លាញ់ ឬប្រេងឆាបន្តិចជាមួយបន្លែទាំងនោះ វាក៏មានរស់ជាតិឆ្ងាញ់បានដែរ ។"

សូភីទៅដល់ផ្ទះ ។ នាងបានធ្វើម្ហូបពីពងមាន់ និងបន្លែសំរាប់គ្រួសាររបស់នាង ។ ពួកគេអង្គុយបរិភោគអាហារយ៉ាងឆ្ងាញ់ពិសា ។ ទូច និងសូភី ចូលចិត្តហូបសណ្តែកកួរ ។

នៅពេលដែលពួកគេកំពុង បរិភោគអាហារ វុទ្ធីបានជីកជីកំប៉ុសមកដល់ហើយជជែកជាមួយពូហេងមួយសន្ទុះអំពីដំណាំ និងការរាំងស្ងួតនៅឆ្នាំនេះ ។ នៅពេលវុទ្ធីត្រឡប់ទៅផ្ទះវិញ ពូហេងនិយាយថាស្អែកវុទ្ធីនឹងយកម៉ាស៊ីនច្រូតមកជួយច្រូតកាត់កសិផលដែលនៅសេសសល់ពីភាពរាំងស្ងួតរបស់យើង ។ សូភីសង្កេតឃើញឪពុកនាងមានទឹកមុខស្រពាប់ស្រពោន ។







ព្រលឹមស្រាង១ សេរី និងវុទ្ធីមកដល់ ។ ហេង និងវុទ្ធីចាកចេញយ៉ាងប្រញាប់ប្រញាល់ ដើម្បីទៅប្រមូលកសិផលរបស់ពួកគេ ។ រីឯសេរី និងសូភីចាប់ផ្តើមរៀបចំដីដាំដំណាំតាមថ្នាលដែលរៀបចំហើយជាស្រេច ។

សេរីពន្យល់សូភី គួរបង្កើតថ្នាលតូច១នៅក្នុងសួនបន្លែហើយរកបង្គោលឬស្សីសំរាប់ដាក់ដើមប៉េងបោះ ត្រកួន និងបង្កើតថ្នាលធំ១សំរាប់ដាំពោតល្ពៅ និងសណ្តែកកួរ ។

សេរីពន្យល់ថា "ប្រសិនបើឯងដាំដំណាំទាំងអស់នេះនៅក្នុងថ្នាលធំមួយនោះសណ្តែកអាចវៀរឡើងដើមពោត ល្ពៅវៀរលើដីបាន" ។

សូភីបន្លឺសំឡេងយ៉ាងត្រេកអរថា "នេះបងពិតជាឆ្លាតណាស់!"



សេរីនិងសូភីធ្វើការពេញមួយព្រឹកដាស់ដីសំរាប់ធ្វើថ្នាលដំណាំ ។ ពួកគេកាប់ដីយ៉ាងសកម្មដោយមិនគិតពីការនឿយហត់ ។ ពួកគេគាស់កកាយយកដុំថ្មចេញពីថ្នាលហើយរែកទឹកពីក្នុងស្ទឹងស្រោចថ្នាលដំណាំទាល់តែដីជោកមានសំណើមល្អ ។

សេរីបន្លឺឡើងថា "ឥឡូវដល់ពេលដែលត្រូវរោយជីកំប៉ុសហើយ" ។

នៅពេលដែលពួកគេកំពុងតែរោយជីកំប៉ុស
សូភីបានឃើញជន្លេនពិណផ្កាឈូក ។

សូភីបន្លឺសំឡេង "បងសេរីមើលនែ៎ ជន្លេនច្រើនណាស់! ពួកវាស៊ីដំណាំយើងទេ?"

សេរីសើចហើយឆ្លើយថា "ទេ! មិនអីទេ! ពួកវាជាជន្លេនល្អ ។ ពួកវាជួយរំលាយដើមរុក្ខជាតិងាប់ៗអោយទៅជាកំប៉ុស ។"

សូភីញញឹមរួចស្ទាបជន្លេនថ្មីៗ បន្ទាប់មកដាក់ជន្លេនទៅក្នុងដីវិញ ។









មុនពេលសេរី និងវុទ្ធីចាកចេញទៅពួកគេបានបង្ហាញសូភី និងគ្រួសាររបស់នាងអំពីរបៀបគ្របថ្នាលបន្លែដោយប្រើដើមសណ្តែក។  ការធ្វើដូចនេះនាំឱ្យដីត្រជាក់ និងមានសំណើមល្អ។ ពួករុក្ខជាតិនេះអាចក្លាយជាជីកំប៉ុស ជាពិសេសសំណល់ដើមរុក្ខជាតិដែលពួកគេចំអិនបរិភោគកាលយប់មិ្សលមិញ។

សេរីនិយាយថា "ចូរចងចាំនិងត្រូវយកចិត្តទុកដាក់កំចាត់សត្វល្អិតចង្រៃទាំងអស់ដែលអាចបំផ្លាញដំណាំរបស់យើងបាន។ ដង្កូវបាក់ខ្នងនឹងស៊ីស្លឹកហើយសត្វស្រឹងពណ៌បៃតងនឹងបឺតជញ្ជក់ផ្លែដំណាំរបស់យើង។ ឯងត្រូវដើរបេះវាចេញរាល់ថ្ងៃរួចយកមកអោយមាន់ស៊ី"។







មួយរយៈពេលក្រោយមកសួនបន្លែរបស់សូភីចេះតែលូតលាស់ល្អ និងបានផ្ដល់ជាបន្លែស្រស់ៗជាច្រើនមុខដល់គ្រួសាររបស់នាង។ ពួកគេមានបន្លែទុកបំរុងសំរាប់លក់ថែមទៀតផង។ ម្ដាយរបស់សូភីបានចាប់ផ្ដើមធ្វើជ្រក់ត្រសក់ ដែលអ្នកភូមិចូលចិត្តទិញបរិភោគជាប្រចាំ។ មួយឆ្នាំក្រោយមកពួកគេអាចសន្សំលុយបានគ្រប់គ្រាន់សំរាប់ទិញសំភារៈបន្ថែមទៀតសំរាប់ធ្វើសួនបន្លែ និងទិញកង់តូចមួយឱ្យសូភី និងសារ៉េតជិះទៅសាលារៀន។



ឪពុកសូភីបន្លឺឡើង "សួនបន្លែរបស់យើងលូតលាស់ល្អខ្លាំងឡើងៗ ។ ពុកពិតជាមានមោទនភាពចំពោះឯងខ្លាំងណាស់ សូភីកូននឹងក្លាយជាកសិករគំរូ ឬយ៉ាងហោចណាស់ក៏ក្លាយជា អ្នកដាំបន្លែដ៏ប្រសើរមួយរូបពេលកូនធំឡើង ។ ហើយប្រហែលជាកូននឹងក្លាយជាអ្នកជំនាញកសិកម្មមួយរូបដែលនឹងជួយបង្រៀនកសិករដទៃទៀតអោយធ្វើស្រែចំការកាន់តែបានប្រសើរឡើង ។"



សូភីត្រឡប់ទៅកាន់សាលារៀនវិញ រួចអធិប្បាយប្រាប់អ្នកគ្រូរបស់នាងគឺ កញ្ញាសុជាតិ អំពីការងារដែលនាងបានធ្វើនៅពេលដែលនាងមិនបានមកសាលារៀន និងអំពីការបរិភោគអាហារដែលមានជីវជាតិ ។ អាហារទាំងនោះបានជួយអោយម្តាយ និងប្អូនប្រុសតូចនាងមានសុខភាពប្រសើរឡើងវិញ ។ កញ្ញាសុជាតិមានការចាប់អារម្មណ៍យ៉ាងខ្លាំង ហើយសួរសូភីថាតើនាងអាចជួយបង្កើតសួនបន្លែសំរាប់សាលារៀនបានឬទេ?

បន្ទាប់មក កញ្ញាសុជាតិ និងសូភីអង្គុយពិភាក្សាគ្នារៀបចំផែនការសួនបន្លែសាលារៀន ។ ពួកគេត្រូវការចូលរួមពីបណ្តាមិត្តរួមថ្នាក់ទាំងអស់ ។ ពួកគេបានសំរេចចិត្តបង្ហាត់សិស្សទាំងអស់ "អំពីវិធីដាំបន្លែ ដែលមានជីវជាតិល្អនៅតាមផ្ទះ" នៅក្នុងម៉ោងមេរៀនបំណិនជីវិត ។





## បន្លែក្នុងសួនច្បារយើង

(ចង្វាក់រាំវង់)

១- ត្រសក់ត្រឡាចននោង  ត្រប់សណ្តែកទ្រើងពពាយប៉េងបោះ ។

២- ស្ពៃក្តោប សាលាដ ត្រកួនស្រស់  (២ដង)
បន្លែទាំងអស់ផ្តល់ជីវជាតិល្អ ។

៣- យើងត្រូវញ៉ាំហើយខំដាំបន្ត (២ដង)
សុខភាពយើងល្អដោយសារញ៉ាំបន្លែ ។

៤- មិត្តអើយយើងត្រូវតែខំថែរក្សាបន្លែនៅក្នុងសួនច្បារយើង ។

លំនាំបទ: អក្ខរាបងសរសេរទៅ

និពន្ធដោយ: លោក ហ៊ីង គឹមហឿន
ប្រធានការិយាល័យបឋមសិក្សា
នៃមន្ទីអប់រំ យុវជន និងកីឡា
ខេត្តបាត់ដំបង

## សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកអគ្គនាយកមូលនិធិម៉ាដក្សូលីភីត និង បុគ្គលិក ។ លោកនាយក ACIAR បុគ្គលិករបស់សេវាសុខភាពជាតិចក្រភពអង់គ្លេស ទីប្រឹក្សាជាន់ខ្ពស់ ផ្នែកអប់រំនៃ MJP  និង លោកគ្រូ អ្នកគ្រូ ទាំង អស់នៅតំបន់គោលដៅ MJPសំឡូត និងដែល ចំណាយពេលដ៏មានតំលៃខិតខំ យកចិត្តទុកដាក់ និងកំលាំកាយចិត្តរៀបចំក្រងសៀវភៅនេះឡើង ដើម្បីអប់រំផ្សព្វផ្សាយអំពីសារៈសំខាន់នៃកសិកម្ម និងអាហាររូបត្ថម្ភ សំរាប់កុមារ និងប្រជាជន នៅសំឡូត ។

សូមថ្លែងអំណរគុណជាពិសេសដល់បុគ្គលិកដែលមានរាងដូចខាងក្រោម:

. លោក ស្តេហ្វាន់ ប៊ិកណា (អគ្គនាយកនៃមូលនិធិ ម៉ាដក្សូលីភីត)
. លោក បប់ ម៉ាទីន (មជ្ឈមណ្ឌលការកែប្រែឧស្សាហកម្មបឋម)
. អ្នកស្រី ដេបូរ៉ា វ៉ាយ (Whiteout Editing)
. លោក អ៊ួម ណារ៉ុប (អ្នកសំរបសំរួលផ្នែកអប់រំនៃមូលនិធិម៉ាដក្សូលីភីត )
. អ្នកស្រី វិនឌី មែតធ្យូ (ទីប្រឹក្សាផ្នែកអប់រំនៃមូលនិធិម៉ាដក្សូលីភីត)
. អ្នកនាង ស្តេហ្វានី ប៊ិលហ្សៀល (HMAg Pty Ltd)
. អ្នកស្រីហ្វីយូណា ស្កត់ (នាយកដ្ឋាន NSW) នៃកិច្ចការជំនួសនិងការ បណ្តាក់ទុនសេវានិងហេដ្ឋារចនាសម្ពន្ធ័ប្រចាំភូមិភាគ)
. កញ្ញា ថែមស៊ីន ហ្គ្រីហ្វីស (សេវាសុភាពជាតិចក្រភពអង់គ្លេស)
. អ្នកស្រី ចជច្ចេណា ហ៊ិគឃី (ប្រធានផ្នែកបោះពុម្ពផ្សាយរបស់ ACIAR )
. លោក វុធ ម៉ៅ (អ្នកសំរបសំរួលផ្នែកពត៌មានម៉ាដក្សូលីភីត)
និងលោក ចាន់ តូ (អ្នកសំរបសំរួលផ្នែករដ្ឋបាលនៃមូលនិធិម៉ាដក្សូលីភីត)

